**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី

**ការកាត់ដីសរុបទំហំ ទំហំ ១.២៨៥,៦៦ ហិកតា នៅស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ក្នុងនោះ កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ កាត់ចេញពីដីតំបន់ព្រៃការពារ សម្រាប់អភិរក្សធនធានសេនេទិក និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ជាក់ឡាក់ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងការផ្តល់សិទ្ធិ ជាកម្មសិទ្ធិលើក្បាលដី**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល



www.pheakdeylaw.com

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិត ២២៧ លសមគរ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តមណ្ឌលគិរី
- បានឃើញលិខិត ២៣៨ លសមគរ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តមណ្ឌលគិរី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីសរុបទំហំ ១.២៨៥,៦៦ ហិកតា ក្នុងនោះ (១) ទំហំ ៨០៥,៥៤ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ (២) ទំហំ ៤៤៤,១៣ ហិកតា កាត់ចេញពីដីតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិក និង (៣) ៣៥,៩៩ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដាក់ឡាក់ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ១.១៩១,១២ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៩៤,៥៤ ហិកតា រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ នៅភូមិពូរ៉ាដែត ឃុំស្រែអំពូម ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តមណ្ឌលគិរី ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិពូរ៉ាដែត ឃុំស្រែអំពូម ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ។



www.pheakdeylaw.com

**មាត្រា ៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសរុប ៦៥៨ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៦៤៨ ក្បាលដី ជូនប្រជាពលរដ្ឋ ៣៣៧ គ្រួសារ អចលនវត្ថុរបស់វត្ត ០១ ក្បាលដី ដីវិហារព្រះយេស៊ូ ០១ ក្បាលដី និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០៨ ក្បាលដី (ដីប៉ុស្តិ៍រដ្ឋបាល ០១ ក្បាលដី ដីទួលកប់ខ្មោច ០៣ ក្បាលដី ដីមណ្ឌលសុខភាព ០១ ក្បាលដី ដីសាលាឃុំ ០១ ក្បាលដី ដីសាលារៀន ០២ ក្បាលដី) ។

**មាត្រា ៤**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តមណ្ឌលគិរី ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com


1386000
1388000
1390000
1392000
748000
750000
752000
754000
756000
758000
760000
762000

## ផែនទីបង្ហាញក្បាលដីជាន់លើ តំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ សត្វព្រៃមណ្ឌលគិរី គម្របព្រៃឆ្នាំ២០០២ និងក្រុមហ៊ុនសម្បទានសេដ្ឋកិច្ចដាក់ឡាក់ ស្ថិតនៅភូមិពូរ៉ាំងដែត ឃុំស្រែអំពូម ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី



## តារាងឲ្យសម្ព័ន្ធ ភូមិពូរ៉ាដែត WGS_1984

| ល.រ | X | Y | ល.រ | X | Y | ល.រ | X | Y | ល.រ | X | Y |
|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 755299 | 1386812 | 46 | 757101 | 1389512 | 91 | 754268 | 1390618 | 136 | 754849 | 1387091 |
| 2 | 755719 | 1386537 | 47 | 756885 | 1389452 | 92 | 754186 | 1390767 | 137 | 755004 | 1386815 |
| 3 | 755804 | 1386560 | 48 | 756931 | 1389362 | 93 | 753978 | 1390635 | 138 | 755083 | 1387035 |
| 4 | 755861 | 1386684 | 49 | 756898 | 1389331 | 94 | 754012 | 1390870 | 139 | 755243 | 1387463 |
| 5 | 755394 | 1387003 | 50 | 756699 | 1389410 | 95 | 754130 | 1390762 | 140 | 755339 | 1387754 |
| 6 | 756051 | 1386770 | 51 | 756637 | 1389152 | 96 | 754150 | 1390800 | 141 | 755499 | 1387761 |
| 7 | 756110 | 1386595 | 52 | 756660 | 1388999 | 97 | 754059 | 1390951 | 142 | 755574 | 1387828 |
| 8 | 756165 | 1386594 | 53 | 756611 | 1388913 | 98 | 753977 | 1390906 | 143 | 756111 | 1387672 |
| 9 | 756183 | 1386670 | 54 | 756588 | 1388773 | 99 | 753842 | 1391028 | 144 | 756030 | 1387542 |
| 10 | 756250 | 1386773 | 55 | 756539 | 1388782 | 100 | 753593 | 1390693 | 145 | 755778 | 1387666 |
| 11 | 756169 | 1386782 | 56 | 756499 | 1389105 | 101 | 753535 | 1390623 | 146 | 755762 | 1387608 |
| 12 | 756087 | 1386816 | 57 | 756440 | 1389073 | 102 | 753443 | 1390576 | 147 | 756026 | 1387480 |
| 13 | 755652 | 1387303 | 58 | 756213 | 1388857 | 103 | 753432 | 1390544 | 148 | 756043 | 1387425 |
| 14 | 755706 | 1387281 | 59 | 756199 | 1389015 | 104 | 753392 | 1390538 | 149 | 755925 | 1387462 |
| 15 | 755738 | 1387362 | 60 | 756100 | 1389024 | 105 | 753192 | 1390427 | 150 | 755883 | 1387395 |
| 16 | 755843 | 1387428 | 61 | 756088 | 1389296 | 106 | 752874 | 1390716 | 151 | 756023 | 1387329 |
| 17 | 755832 | 1387456 | 62 | 755647 | 1389207 | 107 | 752934 | 1390763 | 152 | 756090 | 1387270 |
| 18 | 755746 | 1387471 | 63 | 755475 | 1389018 | 108 | 753024 | 1390862 | 153 | 757013 | 1387414 |
| 19 | 755760 | 1387434 | 64 | 755445 | 1389069 | 109 | 753092 | 1390931 | 154 | 757217 | 1387429 |
| 20 | 755682 | 1387414 | 65 | 755603 | 1389246 | 110 | 753157 | 1391086 | 155 | 757227 | 1387227 |
| 21 | 756046 | 1387225 | 66 | 755430 | 1389250 | 111 | 753024 | 1391176 | 156 | 757278 | 1387045 |
| 22 | 756195 | 1386975 | 67 | 755466 | 1389268 | 112 | 753151 | 1391299 | 157 | 757456 | 1387060 |
| 23 | 756413 | 1387235 | 68 | 755508 | 1389407 | 113 | 753116 | 1391592 | 158 | 757413 | 1387214 |
| 24 | 756360 | 1387261 | 69 | 755339 | 1389528 | 114 | 753045 | 1391738 | 159 | 757453 | 1387328 |
| 25 | 756398 | 1387367 | 70 | 755257 | 1389527 | 115 | 752870 | 1391861 | 160 | 757566 | 1387389 |
| 26 | 756534 | 1387321 | 71 | 755171 | 1389598 | 116 | 753119 | 1391948 | 161 | 757440 | 1387570 |
| 27 | 756577 | 1387476 | 72 | 755201 | 1389636 | 117 | 753122 | 1392149 | 162 | 757389 | 1387540 |
| 28 | 756540 | 1387505 | 73 | 755411 | 1389548 | 118 | 751722 | 1392141 | 163 | 757352 | 1387720 |
| 29 | 756544 | 1387549 | 74 | 755474 | 1389654 | 119 | 751712 | 1392194 | 164 | 756918 | 1387695 |
| 30 | 756481 | 1387592 | 75 | 754859 | 1389957 | 120 | 751267 | 1391902 | 165 | 757314 | 1389480 |
| 31 | 756457 | 1387659 | 76 | 754717 | 1390001 | 121 | 751475 | 1391574 | 166 | 757317 | 1389300 |
| 32 | 756490 | 1387634 | 77 | 754697 | 1389960 | 122 | 751727 | 1391215 | 167 | 757376 | 1389312 |
| 33 | 756591 | 1387631 | 78 | 754519 | 1390010 | 123 | 751817 | 1390821 | 168 | 757391 | 1389454 |
| 34 | 756601 | 1387665 | 79 | 754540 | 1390170 | 124 | 751842 | 1390556 | 169 | 757713 | 1388960 |
| 35 | 756584 | 1387673 | 80 | 754326 | 1390229 | 125 | 751686 | 1390336 | 170 | 757679 | 1388866 |
| 36 | 756682 | 1387832 | 81 | 754341 | 1390257 | 126 | 752860 | 1389150 | 171 | 757791 | 1388805 |
| 37 | 756770 | 1387817 | 82 | 754294 | 1390275 | 127 | 752817 | 1389016 | 172 | 757901 | 1388785 |
| 38 | 757095 | 1387946 | 83 | 754307 | 1390299 | 128 | 752976 | 1388890 | 173 | 757935 | 1388830 |
| 39 | 756938 | 1388367 | 84 | 754274 | 1390331 | 129 | 753162 | 1388697 | 174 | 758025 | 1388795 |
| 40 | 756961 | 1388425 | 85 | 754297 | 1390386 | 130 | 753630 | 1388452 | 175 | 758021 | 1388775 |
| 41 | 756949 | 1388470 | 86 | 754379 | 1390336 | 131 | 753755 | 1388339 | 176 | 758167 | 1388712 |
| 42 | 756906 | 1388484 | 87 | 754474 | 1390446 | 132 | 753855 | 1388222 | 177 | 758190 | 1388724 |
| 43 | 756840 | 1388674 | 88 | 754382 | 1390496 | 133 | 754263 | 1388014 | 178 | 758399 | 1388487 |
| 44 | 757099 | 1388656 | 89 | 754588 | 1390746 | 134 | 754632 | 1387697 | 179 | 758475 | 1388538 |
| 45 | 757233 | 1389344 | 90 | 754520 | 1390795 | 135 | [illegible] | 1387373 | 180 | 758401 | 1388644 |



www.pheakdeylaw.com

| ID | X | Y | ID | X | Y | ID | X | Y | ID | X | Y |
|---|---|---|---|---|---|---|---|---|---|---|---|
| 181 | 758301 | 1388727 | 191 | 757821 | 1389165 | 201 | 758508 | 1389715 | 211 | 759317 | 1389875 |
| 182 | 758374 | 1388927 | 192 | 757878 | 1389014 | 202 | 758557 | 1389868 | 212 | 759285 | 1390307 |
| 183 | 758292 | 1388967 | 193 | 757858 | 1388891 | 203 | 758612 | 1389784 | 213 | 758771 | 1390172 |
| 184 | 758196 | 1388850 | 194 | 758188 | 1389078 | 204 | 758520 | 1389551 | 214 | 758507 | 1390035 |
| 185 | 758073 | 1388871 | 195 | 758224 | 1389009 | 205 | 758639 | 1389537 | 215 | 758480 | 1389912 |
| 186 | 758092 | 1388909 | 196 | 758405 | 1389166 | 206 | 758637 | 1389587 | 216 | 758207 | 1389753 |
| 187 | 758054 | 1388926 | 197 | 758273 | 1389170 | 207 | 758754 | 1389613 | 217 | 758031 | 1389832 |
| 188 | 758057 | 1389010 | 198 | 758061 | [illegible] | 208 | 758788 | 1389793 | | | |
| 189 | 757955 | 1389212 | 199 | 758200 | [illegible] | 209 | 759036 | 1389659 | | | |
| 190 | 757822 | 1389210 | 200 | 758417 | 1389658 | 210 | 759174 | 1389755 | | | |

មណ្ឌលគីរី, ថ្ងៃទី.១៦....ខែ.ធ្នូ..ឆ្នាំ២០១៣

**វាស់វែងដោយ**

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត

**ប្រធាន**

**ឈឹម_ភាន**

លេខ.២២៧.......លសមគរ

**បានឃើញ និងឯកភាព**

**អភិបាលខេត្ត**

**អេង_ប៊ុនហ៊ាន**



www.pheakdeylaw.com